**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**កំពង់ផែស្វយ័តភ្នំពេញ**

លេខ: ០៩៥.០៧.......ក.ស.ភ.

ថ្ងៃព្រហស្បតិ៍ ៥កើត ខែអស្សុជ ឆ្នាំវក ព.ស.២៥៦០

រាជធានីភ្នំពេញ, ថ្ងៃទី០៦ ខែតុលា គ.ស.២០១៦

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## ការចុះហត្ថលេខារវាងកំពង់ផែស្វយ័តភ្នំពេញ

## ជាមួយនឹងក្រុមហ៊ុន Global Logistic Service Co., Ltd (GLS)

នាព្រឹកថ្ងៃទី៦ ខែតុលា ឆ្នាំ២០១៦ នៅទីស្នាក់ការកណ្តាលនៃកំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ.) ជិតគល់ស្ពានជ្រោយចង្វារ ក.ស.ភ. បានចុះហត្ថលេខាលើកិច្ចសន្យាស្តីពីការលើកដាក់កុងតឺន័រ និងសេវាកម្មចំណតផែ ជាមួយក្រុមហ៊ុន Global Logistic Service Co., Ltd (GLS) នៃសាធារណរដ្ឋសង្គមនិយមវៀតណាម។ កន្លងមក មានក្រុមហ៊ុនប្រតិបត្តិករសាឡង់ដឹកជញ្ជូនកុងតឺន័រចំនួនបីក្រុមហ៊ុន រួមមានក្រុមហ៊ុន Gemadept, ក្រុមហ៊ុន New Port Cypress, និងក្រុមហ៊ុន Sovereign ដែលបាននិងកំពុងប្រើប្រាស់សេវាកម្មលើកដាក់កុងតឺន័រ និងសេវាកម្មចំណតផែរបស់ ក.ស.ភ. ដោយធ្វើការដឹកជញ្ជូនតាមផ្លូវទន្លេមេគង្គតែមួយ ទាំងនៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា និងនៅក្នុងទឹកដីនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ហើយមានការតភ្ជាប់ពី ក.ស.ភ. ទៅកាន់កំពង់ផែមេកៃម៉េប (Cai Mep) នៃប្រទេសវៀតណាមតែប៉ុណ្ណោះ។

ក្រុមហ៊ុន GLS ជាក្រុមហ៊ុនប្រតិបត្តិករសាឡង់ដឹកជញ្ជូនកុងតឺន័រ (Barge Operator) ថ្មីមួយទៀត ដែលនឹងប្រើប្រាស់ផ្លូវដឹកជញ្ជូនថ្មី ដោយប្រើប្រាស់ផ្លូវដឹកជញ្ជូនតាមទន្លេមេគង្គនៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា និងទន្លេបាសាក់នៅក្នុងទឹកដីនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ហើយនឹងមានការតភ្ជាប់ចំនួនពីរ៖

- ពី ក.ស.ភ. ទៅកាន់កំពង់ផែកាន់ធឺ (Can Tho) រួចទៅតភ្ជាប់ទៅកាន់កំពង់ផែមេកៃម៉េប (Cai Mep) នៃប្រទេសវៀតណាម
- ពី ក.ស.ភ. ទៅកាន់កំពង់ផែកាន់ធឺ (Can Tho) រួចភ្ជាប់ត្រង់ទៅកំពង់ផែមេនៅប្រទេសសឹង្ហបូរី។

ក្រុមហ៊ុន GLS នឹងចាប់ផ្តើមដំណើរការផ្តល់សេវាកម្មដឹកជញ្ជូនកុងតឺន័រតាមផ្លូវដឹកជញ្ជូនថ្មី និងការតភ្ជាប់ថ្មីនេះ ចាប់ពីខែតុលា ឆ្នាំ២០១៦ នេះតទៅ។

**កំពង់ផែស្វយ័តភ្នំពេញ**

ទីស្នាក់ការកណ្តាល: អគារលេខ ៦៤៩ តិវៈវិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ/ទូរសារ (៨៥៥) ៤២៧ ៨០២ Email: ppapmpwt@online.com.kh / info@ppap.com.kh